ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៦ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១ . ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តម ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៥រូប និងតាមប្រព័ន្ធអនឡាញចំនួន៣៥រូប សរុបចំនួន៧០រូប។

**៤. របៀបវារៈ៖**ពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាព នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០២២ បង្ហាញដោយ ឯកឧត្តមវេជ្ជ. ទេព ណារុធ ប្រធាននាយកដ្ឋានផែនការ តាមដាន ស្រាវជ្រាវ និងវាយតម្លៃ។ប្រធានបទដែលលើកយកមកបង្ហាញមាន:

៤.១. បច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

៤.២ សកម្មភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍តាមយុទ្ធសាស្រ្ត

៤.៣ បញ្ហាប្រឈម និងជំហានបន្ទាប់

៤.៤ ទិសដៅអនុវត្តបន្ត

**៥. លទ្ធផល ៖**

៥.១ ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត ប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់សមាជិកលេខាធិការដ្ឋានទាំងអស់ ដែលបានផ្តល់របាយការណ៍ទាន់ពេលវេលា ព្រមទាំងបានជម្រាបជូនដល់សមាជិកពីការវាយតម្លៃដាក់ពិន្ទុទៅដល់សមាជិកក្រុមការងារ ដែលបានអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានតាមផែនការកំណត់ និងត្រូវបានផ្តល់ការលើកទឹកចិត្ត។

៥.២ ឧត្តមវេជ្ជ. ទេព ណារុធ ប្រធាននាយកដ្ឋាផែនការ តាមដាន ស្រាវជ្រាវ និងវាយតម្លៃ ធ្វើបទបង្ហាញស្តីពី របាយការណ៍វឌ្ឍនភាព នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០២២។

៥.៣ កែសម្រួល និងបន្ថែមធាតុចូលមួយចំនួន លើទិន្នន័យនៃការឆ្លងថ្មីនៃមេរោគអេដស៍ និងជំងឺអេដស៍

៥.៤ កែសម្រួល និងបន្ថែមជាតុចូលមួយចំនួនលើទិន្នន័យនៃចំនួនគ្រួសារផ្ទុកមេរោគអេដស៍ ដែលទទួលបានការបើកសាច់ប្រាក់ក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

៥.៥ បញ្ហាដែលគួរបារម្ភគឺ ការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅមានកម្រិតខ្ពស់នៅឡើយ តើយើងត្រូវរកវិធីដោះស្រាយយ៉ាងណា?

៥.៦ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ថា ក្រសួងបានធ្វើសមាហរណកម្មបញ្ហាសុខភាពក្នុងគ្រប់កម្រិត ប៉ុន្តែសុខភាពផ្លូវភេទ កាមរោគ ជំងឺអេដស៍ និងគ្រឿងញៀន នៅថ្នាក់៥ និង ថ្នាក់ទី១២

៥.៧ ដើម្បីឱ្យមានព័ត៌មានបន្ថែមគ្រប់ជ្រុងជ្រោយ កិច្ចប្រជុំសម្រេចជូនសមាជិកផ្តល់យោបល់ជាធាតុចូលតាមរយៈតេលេក្រាម ក្រុមប្រឹក្សាបច្ចេកទេស ដែលកំណត់យកត្រឹមម៉ោង៥:០០ នាទីល្ងាច ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ។

៥.៨ ដើម្បីឱ្យមានការសហការគ្នាល្អ សូមមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការជាមួយនិងអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ក្នុងការផ្តល់សេវាដល់ជនជាប់ឃុំ ដែលរស់នៅជាមួយមេរោគអេដស៍ សព្វថ្ងៃមានប្រមាណចំនួន៤៥០នាក់ ។ចំនុចទាំងនេះគួរតែដាក់បញ្ចូលក្នុងរបាយការណ៍ផងដែរ។

៥.៩ កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ បានឯកភាពលើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០២២ សម្រាប់រាយការណ៍នឹងដាក់ជូនកិច្ចប្រជុំពេញអង្គលើកទី១នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់ការអនុវត្តបន្ត៕

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**

**ប្រធានអង្គប្រជុំ**

**ឈឹម ឃិនដារ៉េត**